# ការសិក្សាស្រាវជ្រាវរុករកស្ថានីយបុរាណ ក្នុងស្រុកបារាយណ៍ ខេត្តកំពង់ធំ

**(ភាគ១)**

ដោយ : **បណ្ឌិត ផុន កសិកា**

*ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

*រាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្តីផ្តើម

*ការសិក្សាស្ថានីយបុរាណវត្ថុវិទ្យា ផ្តល់នូវវិភាគទានជាព័ត៌មានដ៏មានតម្លៃ សម្រាប់បេតិកភណ្ឌវប្បធម៌។ ការរកឃើញស្ថានីយបុរាណនានាគឺជាប្រភពមួយផ្សេងទៀត ដែលអាចប្រើប្រាស់បានសម្រាប់កសាងប្រវត្តិសាស្ត្ររបស់ប្រទេសនីមួយៗ។ លក្ខខណ្ឌនានានៃភាពគង់វង្សដែលមាននៅក្នុងស្ថានីយ គឺមានសារសំខាន់ ពិសេសបំផុត ដែលក្រុមអ្នកជំនាញបុរាណវត្ថុវិទ្យាអាចរុករកឃើញស្ថានីយ និងសារសំខាន់របស់ស្ថានីយ។ ភាគច្រើននៃការសិក្សាខាងបុរាណវត្ថុវិទ្យា គឺធ្វើការវិភាគលើបុរាណវត្ថុសិល្បៈ និងសំណល់វត្ថុបុរាណ វត្ថុបរិស្ថានធម្មជាតិ ដែលគេបានរកឃើញនៅក្នុងស្ថានីយ ព្រមទាំងសិក្សាអំពីទិដ្ឋភាពជុំវិញស្ថានីយ។ ការងារដំបូងរបស់បុរាណវត្ថុវិទ្យា ត្រូវធ្វើការរុករកនូវស្ថានីយបុរាណឱ្យឃើញច្រើន តាមដែលអាចទៅធ្វើបាន និងធ្វើផែនទីកំណត់ទីតាំងឱ្យបានមុនការបំផ្លាញដោយសារសកម្មភាពនានា។*

*ដើម្បីដំណើរការងារឱ្យបានសម្រេចជោគជ័យ ក្រុមអ្នកជំនាញបុរាណវត្ថុវិទ្យាជាច្រើន ក៏ពឹងផ្អែកទៅលើបច្ចេកវិជ្ជានិងឧបករណ៍ស្រាវជ្រាវ ដើម្បីជួយដល់ការស្រាវជ្រាវរុករក។*

*អត្ថបទស្រាវជ្រាវមួយនេះទទួលបានលទ្ធផលពីការចុះសិក្សាស្រាវជ្រាវរុករកស្ថានីយបុរាណ ប្រាសាទបុរាណ ទីទួលបុរាណ ដែលជាភូមិដ្ឋានមនុស្សរស់នៅ ត្រពាំងបុរាណ និងវត្ថុបុរាណដែលមាននៅក្នុងស្រុកបារាយណ៍ ខេត្តកំពង់ធំ។ ការសិក្សាស្រាវជ្រាវធ្វើឡើងនៅឆ្នាំ២០០៦ ដែលពេលនោះរាជរដ្ឋាភិបាលមិនទាន់បង្កើតស្រុកតាំងគោកនៅឡើយទេ។ ឃុំមួយចំនួនដែលស្ថិតក្នុងស្រុកតាំងគោកបច្ចុប្បន្នគឺជាអតីតឃុំក្នុងស្រុកបារាយណ៍។*

*ការសិក្សាស្រាវជ្រាវនេះបានប្រើវិធីសាស្ត្របែបបុរាណវិទ្យា គូបង់បាតស្ថានីយ ធ្វើផែនទីតាំងស្ថានីយ ធ្វើសម្ភាសន៍ជាមួយអ្នកស្រុកចាស់ទុំដែលរស់នៅជិតស្ថានីយ*

បុរាណ។ ការសិក្សាស្រាវជ្រាវនេះក៏ប្រើរូបថតលើអាកាស តាមរយៈ Google Earth និងផែនទីជាឧបករណ៍និងជាមគ្គុទេសក៍សំខាន់ដែលបង្ហាញពីពត៌មានអត្តសញ្ញាណស្ថានីយ។ ការសិក្សាស្រាវជ្រាវអំពីប្រាសាទបុរាណ ទីទួលបុរាណ និងស្ថានីយបុរាណផ្សេងទៀតក៏ច្រើនពឹងផ្អែកលើឯកសាររបស់លោក Etienne Aymonier (1900)[1] និងលោក Lunet de Lajonquière (1902)[2] ដែលបានចុះបញ្ជីប្រាសាទក្នុងប្រទេសកម្ពុជាជាច្រើន។ យ៉ាងណា ឯកសារទាំង២នេះមិនមានប្រាសាទ ទួលគ្រឹះប្រាសាទ និងស្ថានីយបុរាណច្រើននោះទេ លើកលែងប្រាសាទត្នោតជុំ (ត្នោតជុំលិច និង ត្នោតជុំជើង) វត្តជ្រលង វត្តបារាយណ៍។

ការសិក្សាស្រាវជ្រាវនេះនឹងបង្ហាញប្រាសាទមួយចំនួន ព្រមទាំងគ្រឹះប្រាសាទ ក៏ដូចជាស្ថានីយបុរាណជាច្រើនទៀតក្នុងស្រុកបារាយណ៍ ខេត្តកំពង់ធំ។

[1] Aymonier, Etinne., Le Cambodge I Le Royume Actuel, Paris, 1900

[2] Lajonquière, E. Lunet., Invenaire Descriptif des Monuments du Cambodge, Tome I, 1902.

## ទីតាំងភូមិសាស្ត្រ

ស្រុកបារាយណ៍[3]នៃខេត្តកំពង់ធំ មានឃុំចំនួន១៨ជារចនាសម្ព័ន្ធ ដូចជា : ឃុំបាក់ស្នា ឃុំក្រវ៉ា ឃុំគគីធំ ឃុំចើងដើង ឃុំបល្ល័ង្គ ឃុំត្នោតជុំ ឃុំចុងដូង ឃុំបឹង ឃុំបារាយណ៍ ឃុំឈូក ឃុំទ្រៀល ឃុំស្រឡៅ ឃុំជ្រលង ឃុំអណ្តូងពោធិ៍ ឃុំសូយោង ឃុំប្រនៀង ឃុំស្វាយភ្លើង និងឃុំពង្រ។




ផែនទីស្រុកបារាយណ៍ ខេត្តកំពង់ធំ (ឆ្នាំ២០០៧)

[3] ការសិក្សាស្រាវជ្រាវបានអនុវត្តក្នុងឆ្នាំ២០០៧។ បន្ទាប់ពីរដ្ឋាភិបាលកម្ពុជាបង្កើតស្រុកតាំងគោក ឃុំមួយចំនួនបានកាត់ចូលក្នុងស្រុកតាំងគោក (អនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃអង្គារ ៣កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី៨ ខែមករា ឆ្នាំ២០១៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតស្រុកតាំងគោក នៃខេត្តកំពង់ធំ) ដូចជាឃុំពង្រ ឃុំប្រនាង ឃុំជ្រលង ឃុំទ្រាល ឃុំស្រឡៅ ឃុំសូយោង ឃុំស្វាយភ្លើង និងឃុំអណ្តូងពោធិ៍។

## លទ្ធផលនៃការសិក្សាស្រាវជ្រាវ៖

### ១. ទួលសាឡុំចាស់ ឬទួលចាស់

ទួលសាឡុំចាស់ ស្ថិតនៅក្នុងភូមិបឹងខាងជើង ឃុំបឹង។ នៅខាងត្បូងទួលមានស្រះមួយមានឈ្មោះថា «ស្រះវែង»។ នៅពីមុខសាឡុំមានស្រះមួយដែរ ឈ្មោះថា «ស្រះខ្វី»។ តាមរយៈទិដ្ឋភាពជាក់ស្តែងបង្ហាញថា ទួលនេះពុំមានគូទឹកព័ទ្ធជុំវិញទេ។ ប្រជាពលរដ្ឋបានរួមគ្នាកសាងនៅលើទួលមានសាឡុំ សម្រាប់គោរពបូជាតាមបែបពុទ្ធសាសនា ដោយមានសាងសន្ទឹកសីមាព័ទ្ធជុំវិញសាឡុំនោះ។ សន្ទឹកសីមាដែលតម្កល់នៅភាគឦសាន មានទម្រលិង្គមួយ។ នៅក្នុងសាឡុំមានបំណែកថ្មភក់មួយដុំ ត្រូវបានគេដាក់ឆ្លាក់ជាព្រះពុទ្ធបដិមា គ្រង់ស្បង់ជីពរ។



ព្រះពុទ្ធបដិមាត្រូវបានគេដាប់ពីបំណែកថ្មភក់




ប្លង់ទួលសាឡុំចាស់





ទម្រលិង្គនៅភាគខាងឦសានសាឡុំចាស់

## ២. វត្តបឹងត្បូង

វត្តបឹងខាងត្បូង ស្ថិតនៅក្នុងភូមិបឹងខាងត្បូង ឃុំបឹង។ នៅខាងលិចព្រះវិហារមានសំណល់វត្ថុមួយចំនួន ដែលស្ថិតទីតាំងប្រាសាទចាស់ដែលត្រូវបានរុះរើក្នុងអំឡុងជាង១០ឆ្នាំមុន ដោយដឹកនាំដោយលោកអាចារ្យម្នាក់។ នៅក្បែរនេះមានរូបបដិមាព្រះបាទជ័យវរ្ម័នទី៧សាងពីស៊ីម៉ង់ត៍ ដែលប្រើទម្របដិមា និងថ្មភក់ប្រាសាទចាស់ធ្វើជាបល្ល័ង្គ ច្រើនជាន់ថ្នាក់។ នៅក្នុងបរិវេណកុដិមានវត្ថុសិល្បៈអំពីថ្មភក់មួយចំនួន។ នៅក្រោមដើមពោធិ៍មួយ ខាងត្បូងព្រះវិហារមានសិលាចារឹកមួយផ្ទាំងប្រហែលចារនៅក្នុងសតវត្សទី៦-៧ ត្រូវបានគេលាបថ្នាំពណ៌មាស ប្រើជាបង្អែកព្រះពុទ្ធបដិមាស៊ីម៉ង់ត៍ពណ៌មាសមួយអង្គនោះ។

ក្រៅពីនេះ យើងប្រទះឃើញនូវបំណែករូបពងកាយទេវរូបតូចៗមួយចំនួនដែលគេដាក់បណ្តុបលើគ្នាក្បែររូបសំណាកព្រះបាទជ័យវរ្ម័នទី៧។ រីឯនៅខាងមុខរូបសំណាកនេះ មានផ្តែរមួយលម្អដោយក្បាច់ចម្លាក់ក្នុងរចនាបថសម្បូរព្រៃគុក។ មានបំណែកសសរពេជ្រ, ថ្មអឌ្ឍចន្ទ្រ ចម្លាក់ក្រឡោត ថ្មកំពូលប្រាសាទ សន្ទឹកសីមានិងស្តូបចេតិយ (ប្រហែលសម័យកសាងក្នុងកណ្តាល)។





រូបសំណាកព្រះបាទជ័យវរ្ម័នទី៧ និងសិលាចារឹក ដែលធ្វើជាបង្អែកព្រះពុទ្ធបដិមា



រូបភាពគំនរវត្ថុសិល្បៈ



ចម្លាក់ក្រឡោតទាប



បំណែកឥដ្ឋ (ឥដ្ឋប្រាសាទ) នៅលើទួលស្វែង

## ៣. ទួលស្វែង

ទួលស្វែងស្ថិតនៅក្នុងឃុំបឹង ស្ថិតនៅភាគអាគ្នេយ៍នៃបឹង (បឹងខាងត្បូងវត្តបឹងត្បូង)។ នៅលើផ្ទៃលើរបស់ទួលស្វែង មានបំណែកឥដ្ឋខ្ទះៗ។ ទួលនេះ មិនាមនស្លាកស្នាមបញ្ជាក់ថា មានគូទឹកព័ទ្ធជុំវិញទេ។ តាមព័ត៌មានរបស់អ្នកភូមិ បញ្ជាក់ថា ទួលនេះធ្លាប់មានអ្នកជីកបំផ្លាញរកវត្ថុបុរាណ ដែលត្រូវគ្នានឹងភស្តុតាងរណ្តៅបន្សល់ទុកដល់បច្ចុប្បន្ន។ តាមរយៈទិដ្ឋភាពនេះ យើងអាចសន្និដ្ឋានបានថា ទួលនេះប្រហែលជាទួលប្រាសាទ។ នៅខាងលិចទួលនេះ មានទួលមួយទៀតដែលមានឈ្មោះថា ទួលត្រពាំងសំរោង។



ស្លាកស្នាមជីកកកាយនៅលើទួលស្វែង

## ៤. ទួលសែនហាយ

ទួលសែនហាយ ស្ថិតនៅក្នុងភូមិបឹងខាងជើងវត្តបឹង។ នៅលើទួលនេះ មានថ្មអឌ្ឍចន្ទ្រ ទម្របដិមា និងបំណែកសសរពេជ្រ។ លក្ខណៈនៃសសរពេជ្រ មានសណ្ឋានរាងមូល ដែលជាលក្ខណៈសសរពេជ្រសម័យមុនអង្គរ។ នៅទីនោះដែរ មានដើមពោធិ៍ធំមួយដុះនៅលើគ្រឹះប្រាសាទ ដែលជាប្រភេទថ្មបាសាល់។ ទួលនេះ មានសំណង់ខ្ទមអ្នកតាសែននិងយាយហាយ ដែលអ្នកភូមិកំពុងប្រតិបត្តិជំនឿជាប្រចាំ។



តូបអ្នកតាសែននិងយាយហាយ



បំណែកសសរពេជ្រ និងទម្របដិមា

## ៥. គុកតាពេជ

គុកតាពេជ ស្ថិតក្នុងភូមិចាន់ក្រហម ឃុំឈូកខ្សាច់ គឺស្ថិតនៅខាងកើតផ្លូវជាតិ ខាងកើតសាលាស្រុកបាពាយណ៍ចម្ងាយ ប្រមាណ៥គ.ម.។ នៅលើទួលគុក មានផ្តែរមួយ លម្អដោយចម្លាក់ផ្សេងៗ ក្នុងរចនាបថឃ្លាំង ប្រហែលកសាងនៅក្នុងរាជព្រះបាទសូរ្យវរ្ម័នទី១ នាដើមសតវត្សទី១១។

គុកតាពេជបែរមុខទៅទិសខាងកើត មានក្លោងទ្វារចូលទាំងខាងមុខ និងក្រោយ មានកំពែងពីរជាន់ធ្វើពីថ្មបាយក្រៀម មានស្រះពីរដែលស្រះទីមួយតូចដែលកាំជណ្តើរធ្វើអំពីថ្មភក់។ នៅលើទួលគុក មានបំណែកសសពេជ្ររាងអដ្ឋកោណធ្វើពីថ្មភក់ និងមានសំណល់ស៊ុមទ្វារពីថ្មភក់ដែរ។ ចំពោះកំពែងវិញកំពែងទី១នៅសល់រូបរាងច្បាស់ តែកំពែងទី២ ស្ទើរបាត់ស្នាមទាំងស្រុង។

ប្រជាពលរដ្ឋកំពុងប្រើប្រាស់ទីធ្លាក្នុងកំពែងទី២សម្រាប់បញ្ចុះសព។ ជាងនេះទៅទៀត ពួកគាត់យកបំណែកសសរពេជ្រដែលមានរាងអដ្ឋកោណធ្វើជាបង្គោលពីមុខផ្នូរ។ នៅលើទួលមានដើម ស្តង់ធំមួយដុះក្នុងថែវទី៣ដែលជាតួប្រាសាទកណ្តាល។

នៅខាងត្បូងនិងខាងលិចគុកតាពេជ មានទួលខ្ពស់ជាងវាលស្រែ។ ទួលទាំងអស់នោះអាចជាទួលភូមិមនុស្សរស់នៅ។



រូបស៊ុមទ្វារនៅលើទួល



បំណែកសសរពេជ្រដែលប្រើជាបង្គោលផ្នូរខ្មោច



ផ្តែរនៅគុកតាពេជក្នុងរចនាបថឃ្លាំង



ដីទីទួលប្រាសាទក្លាយជាកន្លែងកប់ខ្មោច




ប្លង់ទូទៅនៃគុកតាពេជ

## ៦. តូបអ្នកតាដំបងដែក

តូបអ្នកតាដំបងដែក ស្ថិតនៅក្នុងភូមិក្រូច ឃុំស្វាយភ្លើង។ តូបអ្នកតាតម្កល់ទម្របដិមាថ្មភក់ ដែលអ្នកភូមិអះអាងថា យកមកពីទួលមួយនៅក្បែរនេះ គឺទួលយាយទូត។ ប៉ុន្តែ តាមការចុះទៅពិនិត្យផ្ទាល់នៅទួលយាយទូត ពុំរកស្លាកស្នាមបុរាណនៅលើទួលនេះទេ។



ខ្ទមអ្នកតាដំបងដែកនិងទម្របដិមា

## ៧. វត្តស្រះបន្ទាយឬអម្ពវ័ន្ត

វត្តស្រះបន្ទាយឬវត្តអម្ពវ័ន្ត ស្ថិតនៅក្នុងភូមិស្រះបន្ទាយ ឃុំច្រនៀង។ នៅទីនេះយើងប្រទះឃើញមានបំណែកឥដ្ឋមួយចំនួន ប៉ុន្តែមិនមានវត្ថុបុរាណ ក្រៅពីទម្រ និងសន្ទឹកសីមា ដែលប្រហែលជាសាងនៅសម័យក្រោយមកទៀតតែប៉ុណ្ណោះ។



បំណែកឥដ្ឋក្នុងបរិវេណវត្តស្រះបន្ទាយ



ជើងទម្រសីមានៅក្នុងបរិវេណវត្តស្រះបន្ទាយ

## ៨. ទួលកោះសាលា

ទួលកោះសាលា ស្ថិតនៅក្នុងភូមិឫស្សីលើ ឃុំស្វាយភ្លើង។ សាឡុំនៅលើទួលនេះបានសាងឡើងនៅឆ្នាំ២០០២ ក្រោយពេលសកម្មភាពជីកបំផ្លាញមួយឆ្នាំ។ នៅជុំវិញបរិវេណសាឡុំ មានទម្របដិមាចំនួនពីរដុំ ព្រមទាំងថ្មបាយក្រៀមជាច្រើនដុំ។

ទម្របដិមាមួយ ត្រូវបានប្រើជាទម្របដិមាគេទស្រីធ្វើពីស៊ីម៉ង់ត៍ ស្ថិតនៅក្បែរសាឡុំ។ នៅលើនិងក្បែរបល្ល័ង្កព្រះពុទ្ធបដិមាក្នុងសាឡុំ មានបំណែកព្រះពុទ្ធបដិមាប្រក់នាគក្បាល៧ធ្វើពីថ្មភក់ និងបំណែកថ្មភក់ផ្សេងៗទៀត។



បំណែកព្រះពុទ្ធបដិមាប្រក់នាគធ្វើពីថ្មភក់ ដាក់ក្បែរបល្ល័ង្កព្រះ



ទម្របដិមានៅក្បែរសាឡុំ

### ៩. ទួលវិហារ

ទួលវិហារស្ថិតក្នុងភូមិស្រះបន្ទាយ ឃុំប្រនាង។ ទួលនេះមានស្រែព័ទ្ធជុំវិញ កម្ពស់មួយម៉ែត្រធៀបនឹងភ្លឺស្រែ។ នៅលើទួល មានបំណែកឥដ្ឋ និងថ្មប្រើជាគ្រឹះប្រាសាទ។ ទួលនេះប្រហែលធ្លាប់មានប្រាសាទមួយពីបុរាណតែក្រោយមកក៏ត្រូវដួលរលំ។ ចំណែកបំណែកឥដ្ឋ និងថ្មគ្រឹះប្រាសាទនៅលើទួល ប្រហែលត្រូវបានគេជីកកកាយរកវត្ថុបុរាណ។

សព្វថ្ងៃគេបានប្រើប្រាស់ទួលនេះសម្រាប់ដំណាំស្រូវ និងចម្ការចន្ទី។



ទិដ្ឋភាពទួលវិហារមើលពីចម្ងាយ



ដុំឥដ្ឋប្រាសាទនៅលើទួល

### ១០. ទួលវិហារចាស់

ទួលវិហារចាស់ ស្ថិតក្នុងភូមិសៀមរៀង ឃុំប្រនាង។ ទួលនេះព័ទ្ធជុំវិញដោយគូរទឹក ប៉ុន្តែពុំមានស្លាកស្នាមច្រកចេញចូលទៅទួលនេះទេ។ ទួលនេះ មានត្រពាំងមួយនៅខាងត្បូង និងមួយទៀតនៅភាគខាងជើង ។ នៅលើទួលនេះ មានផ្នូរខ្មោចជាច្រើន។

ទួលនេះមានបន្សល់នូវបំណែកថ្មភក់និងថ្មបាយក្រៀម។



បំណែកថ្មភក់







ប្លង់ទួលវិហារចាស់

## ១១. ទួលស្វាយ

ទួលស្វាយស្ថិតនៅចម្ងាយប្រមាណ ៣០០ម៉ែត្រ ខាងកើតផ្លូវជាតិលេខ៦អា នៅខាងលិចឈាងខាងត្បូងទួលសាលា ព័ទ្ធជុំវិញដោយវាលស្រែ។ តាមរយៈស្នាកស្នាមច្រើនកន្លែងដែលស្នាមជីកកកាយរកវត្ថុបុរាណបង្ហាញពីភស្តុតាងប្រាសាទសាងពីឥដ្ឋ។ ទួលនេះអាចមានតួប្រាសាទមួយចំនួន។ មានបំណែកថ្មបាសាល់ជាច្រើនដែលជាប្រភេទថ្មសម្រាប់ដាក់ក្នុងគ្រឹះប្រាសាទ។



ទួលស្វាយជាមួយនឹងស្នាកស្នាមជីកកកាយ

## ១២. វត្តល្វាកណ្តាល

វត្តល្វាកណ្តាល ស្ថិតនៅក្នុងភូមិរស្មីរំដោះ ឃុំច្រនៀង។ យើងប្រទះឃើញសំណល់នៃស្ថាបត្យកម្មប្រាសាទមានដូចជា ទម្រប់ដិមាមួយ បំណែកថ្មភក់ បំណែកថ្មបាសាល់ និងថ្មបាយក្រៀមមួយចំនួនទៀត។ នៅក្បែរព្រះវិហារមានរោងសាលាមួយដែលមានខឿនសាងពីថ្មបាយក្រៀមដែលប្រហែលគ្នាទៅនឹងថ្មប្រាសាទ។ ជាងនេះទៀត យើងឃើញ មានស្នាកស្នាមគូរទឹកនៅសងខាងវិហារផ្នែកខាងជើងនិងខាងត្បូង។

ដូច្នេះព្រះវិហារនេះប្រហែលជាសង់ពីលើទួលប្រាសាទចាស់។



បល្ល័ង្កជាទម្រង់បដិមា និងខឿនសំណង់មួយនៅក្នុងបរិវេណវត្ត

## ១៣. វត្តស្វាយជីអោក

នៅក្នុងបរិវេណវត្តស្វាយជីអោក យើងអាចរកឃើញថ្មភក់ជាច្រើនដុំដូចជា ផ្តែរ សសរពេជ្រ សិលាចារឹក ទម្របដិមា និងឧបករណ៍កិនថ្នាំ។ បំណែកសសរពេជ្រ និងផ្តែរយកពីទួលមួយក្នុងភូមិស្វាយជីអោក ដែលស្ថិតនៅខាងក្រោយវត្ត។ រីឯសិលាចារឹកត្រូវបានគេប្រើជណ្តើរសម្រាប់ឡើងទៅសាលាឆាន់។ តួអក្សរចារលើសិលាចារឹកជាប្រភេទអក្សរសម័យមុនអង្គរ មានឃ្លាមួយមានសរសេរ ពាក្យ «កម្រតាង អញ» ។

ចំណែកឯទម្របដិមា ថ្មកិនថ្នាំ និង បំណែកសសរពេជ្រផ្សេងទៀត គេដាក់ផ្តុំគ្នានៅក្នុងពេងអ្នកតាមួយក្នុងវត្តស្វាយជីអោកនេះដែរ។



ផ្ទាំងសិលាចារឹក



បំណែកសសរពេជ្រផ្តែរដែលយកមកពីទួលមួយខាងក្រោយវត្ត





ទម្របដិមា បំណែកសសរពេជ្រ និងថ្មកិនថ្នាំនៅក្នុងពេងអ្នកតា

## ១៤. ទួលគុក ឬទួលគុកបល្ល័ង្គ

ទួលគុកឬទួលគុកបល្ល័ង្គ ស្ថិតក្នុងភូមិប្រខ្នាយ ឃុំទ្រៀល។ ទួលនេះត្រូវបានគេជីកកកាយនៅទសវត្សឆ្នាំ១៩៩០។ យើងឃើញមានគ្រឿងសំណង់ប្រាសាទ ដូចជា សសរពេជ្រ ផ្តែរ និងស៊ុមទ្វារ នៅឈរនៅឡើយ។ នៅផ្នែកខាងលើនៃចម្លាក់ផ្តែរមានប្រណាមចំនួន១៥។ ចំណែកឯនៅចំកណ្តាលក្បាច់ផ្តួង មានរូបព្រះឥន្ទ្រជិះដំរីក្បាលបី។ នៅសងខាងទ្វារមានសំណល់ថ្មបាយក្រៀមពីរដួរ។

លក្ខណៈសំណង់ និងចម្លាក់របស់ទួលគុក បង្ហាញឱ្យឃើញថាប្រាសាទនេះធ្វើឡើងទៅតាមសម័យកាល ឬរចនាបថច្បាស់លាស់មួយ ប៉ុន្តែគ្រាន់ប្រាសាទនេះមិនបានកសាងឱ្យបានធំដូចប្រាសាទនៅតាមតំបន់រមណីយដ្ឋានធំៗ នោះទេ។ គេបានកសាងឡើងគឺដើម្បីសម្រាប់ធ្វើការគោរពបូជាតូចមួយនៅក្នុងតំបន់នេះតែប៉ុណ្ណោះ។ ទួលគុក ប្រហែលកសាងតាមលំនាំរចនាបថចុងកោះកេរ[4]? ដោយសារក្បាច់រចនាលើផ្តែរ និងលក្ខណៈសំណង់ស្ថាបត្យកម្មនិងចម្លាក់ ពិសេសនៅពីមុខប្រាសាទមានថ្នាលយមកមុខ ប្រមាណ៥០ម៉ែត្រ រីឯនៅផ្នែកខាងកើតមានស្រះមួយនៅអ័ក្សកើតទៅលិច។

នៅជុំវិញតំបន់នេះ មានទួលសាឡុំ តាជំពូ គុកត្រពាំងស្នួង និងទួលព្រៃវិហារ។



ទួលគុកបល្ល័ង្គនិងមេទ្វារ



ផ្តែររចនាបថកោះកេរនៅលើមេទ្វារនៃគុកបល្ល័ង្គ




ផ្តែររចនាបថកោះកេរ(ប្រភព: Boisselier, p. 151)




ប្លង់ទូទៅនៃទួលគុក ឬ គុកបល្ល័ង្គ

4 សូមអាន Jean Boisselier, Asie du Sud-Est : I. Le Cambodge, 1966, p. 151-152

## ១៥. សាឡុំតាជំពូ

សាឡុំតាជំពូ ស្ថិតនៅភាគឦសាន ភូមិប្រខ្នាយ ឃុំទ្រៀល។ នៅក្នុងសាឡុំនេះ មានសំណល់បល្ល័ង្គ និងថ្មប្រាសាទ ដែលត្រូវបានកែច្នៃទៅជាព្រះពុទ្ធបដិមាសម្រាប់គោរពបូជានៅក្នុងសាឡុំនេះ។ ក្រៅពីនេះ មានបំណែកថ្មភក់មួយចំនួននៅខាងក្រោយបល្ល័ង្គព្រះ។ ចំណែកស៊ុមទ្វារអំពីថ្មភក់ត្រូវបានប្រជាជនកែច្នៃ និងកសាងឡើង ជាព្រះពុទ្ធបដិមា។ រីឯទម្របដិមាធំមួយត្រូវបានប្រើជាបល្ល័ង្គសម្រាប់តម្កល់ព្រះពុទ្ធបដិមា។

តាមរយៈការពិនិត្យទិដ្ឋភាពខាងក្រៅបញ្ជាក់ឱ្យដឹងថាសាឡុំហាក់ដូចជាពុំបង្ហាញឱ្យឃើញអំពីលក្ខណៈជាស្ថានីយបុរាណទេ។ ប៉ុន្តែទីតាំងនេះ ក៏មានថ្មភក់ប្រាសាទបុរាណមួយចំនួន នៅក្នុងសាឡុំ និងត្រូវបានប្រើក្នុងគោលបំណងផ្សេងៗ។



បល្ល័ង្គប្រើជាទម្រព្រះពុទ្ធបដិមា



ព្រះពុទ្ធបដិមាដែលកែច្នៃពីស៊ុមទ្វារប្រាសាទ

## ១៦. ទួលព្រៃវិហារ

ទួលព្រៃវិហារ ស្ថិតនៅខាងជើងភូមិប្រខ្នាយ។ ការសិក្សាផ្ទៃលើ យើងបានប្រទះឃើញសំណល់ថ្មបាយក្រៀម និងបំណែកឥដ្ឋប្រាសាទ និងស្នាមជីកកកាយរកវត្ថុបុរាណដោយឃើញមានថ្មគ្រឹះប្រាសាទរាយប៉ាយលើទួល។ ទួលនេះ ព័ទ្ធជុំវិញដោយវាលស្រែ។ ទួលនេះមិនមានស្លាកស្នាមគូទឹកទេ។



ទិដ្ឋភាពទួលព្រៃវិហារ និងរណ្ដៅជីកកកាយ
មានបំណែកថ្មបាយក្រៀមនិងឥដ្ឋ

## ១៧. វត្តជ្រលង

វត្តជ្រលង ស្ថិតក្នុងភូមិសិរីចំប៉ា ឃុំជ្រលង។ តាមរយៈការគោរពបូជាតៗគ្នារបស់ប្រជាជនខ្មែរតែងធ្វើការគោរពបូជានៅទីកន្លែងស័ក្តិសិទ្ធ ជាពិសេសជាកន្លែងដែលបន្តពីបុរាណមក។ យ៉ាងណាមិញ ព្រះវិហារភាគច្រើន ដូនកាលត្រូវបានសាងសង់នៅលើទីទួលឬទីតាំងប្រាសាទបុរាណ។

តាមរយៈសំណល់បុរាណដែលមាននៅសេសសល់នៅក្នុងបរិវេណវត្តជ្រលង មានដូចជាតោថ្ម[5]ចំនួនពីរដែលមួយនៅក្បែរកុដិនិងមួយទៀតស្ថិតនៅលើខឿនព្រះវិហារ និងសំណល់ថ្មបាយក្រៀមជាច្រើនដុំសង់តម្រៀបជុំវិញដើមពោធិ៍ខាងលិចព្រះវិហារ ដែលទាំងអស់នេះគឺជាភស្តុតាងនៃស្ថានីយបុរាណ។ តោថ្មត្រូវបានគេលាបលម្អពណ៌មាស និងដាក់តាំងនៅលើខឿនព្រះវិហារ។



សំណល់ថ្មបាយក្រៀមតម្រៀបជុំវិញដើមពោធិ៍



តោសាងពីថ្មភក់ក្នុងវត្តជ្រលង

## ១៨. គុកម្រេញ និងតំបន់ជុំវិញ

តាមរយៈអ្នកភូមិជុំវិញតំបន់នេះហៅឈ្មោះគុកនេះថា «គុកម្រេញ» ប៉ុន្តែសម្រាប់ការសរសេរអាផ្វាធរបានហៅថា «គុហ៍បាវែង»។

គុកម្រេញស្ថិតក្នុងភូមិជៀបឃុំជ្រលង។ គុកនេះជាប្រភេទទួលខ្ពស់មានវាលស្រែជុំវិញ។ នៅខាងមុខគុក មានសាឡុំមួយ និងមានបំណែកព្រះកេសបដិមាថ្មភក់ និងចម្លាក់ក្រឡោតទេពប្រណមមួយ។

ចំណែកសំណល់ស្ថាបត្យកម្មវិញ មានសល់ស៊ុមទ្វារឈរនៅឡើយ ។ រីឯផ្តែរធ្លាក់រលំមកលើដី។ ក្បាច់និងក្បាច់រចនានៅលើផ្តែរបង្ហាញពីលក្ខណៈចម្លាក់នៅក្នុងរចនាបថចុងបន្ទាយស្រី ដោយក្បាច់លម្អប្រកបដោយផ្កាភ្ញី រីឯនៅកណ្តាលមានរូបព្រះឥន្ទ្រជិះដំរី និងមានសឹង្ហពីរនៅអមដំរីខ្ជាក់ផ្កា។

នៅលើទួលគុក មានកំណាត់សសរពេជ្រដែលមិនទាន់ធ្លាក់ ទម្របដិមា និងថ្មអឌ្ឍចន្ទ្រធ្វើពីថ្មភក់។ យើងសង្កេត

[5] ឯកសាររបស់លោក Lajonquière, E. Lunet., Invenaire Descriptif des Monuments du Cambodge, Tome I, 1902, p. 208 ក៏បានសរសេរដែរថាមានតោថ្មចំនួន២ស្ថិតក្នុងវត្តជ្រលងនេះ។

ឃើញឥដ្ឋប្រាសាទជាច្រើននៅរាយបាយនៅជុំវិញគុក និងថ្មបាយក្រៀមតិចតួចនៅលើទួលដែរ។

ផ្តែរមានលម្អដោយចម្លាក់ផ្កាភ្ញី ដែលនៅកណ្តាលមានរូបព្រះឥន្ទ្រជិះដំរី? (ស្នាមព្រាលៗដោយសារចោរលួចដាប់) សត្វតោពីរនៅអមដំរីខ្ទាក់កាន់ផ្កា និងនៅចុងផ្តែរទាំងសងខាងមានចម្លាក់សត្វគ្រុឌ។ តាមរយៈចម្លាក់លម្អលើផ្តែរទាំងនោះ យើងអាចសន្និដ្ឋានថា ផ្តែរនេះប្រហែលកសាងក្នុងរចនាបថបន្ទាយស្រី? នៅចុងសតវត្សទី១០។ ដូច្នេះ គុហ៍បាវែង ឬ គុកម្រេញ ប្រហែលត្រូវបានកសាងក្នុងចុងសតវត្សទី១០ ក្នុងរចនាបថបន្ទាយស្រី។

នៅខាងកើតគុកម្រេញ មានបឹងមួយឈ្មោះ «បឹងស្មៅ» ។ រីឯនៅខាងជើងវិញមានបឹងមួយឈ្មោះ «បឹងវែង»។ ចំណែកនៅខាងលិចមានចម្ងាយប្រមាណ៥០០ម. មានត្រពាំងពីរគឺ «ត្រពាំងម្រេញតូច» និង «ត្រពាំងម្រេញធំ»។ នៅជាប់ត្រពាំងម្រេញធំផ្នែកខាងលិចមានទួលមួយឈ្មោះ ទួលម្រេញ ដែលជាផ្នែកចុងក្រោយនៃទួលត្រូវបានប្រើប្រាស់ជាឡឥដ្ឋនៅសម័យមុនសង្គ្រាម។

នៅផ្នែកខាងត្បូងឈៀងខាងលិចមានទួលមួយដែលមានឈ្មោះថា «ទួលនាងលក្ខណ៍» ជាទួលគេដាំដំណាំចម្ការចន្ទី។ នៅខាងកើតទួលនេះមានត្រពាំងមួយ។ ទួលនាងលក្ខណ៍ មានគូទឹកព័ទ្ធជុំវិញនិងមានសំណល់ឥដ្ឋប្រាសាទតិចតួចនៅលើទួល។



ទិដ្ឋភាពគុកម្រេញពីខាងមុខ



គុកម្រេញ



ទិដ្ឋភាពទួលម្រេញ



ទួលនាងល័ក្ខណ៍



ប្លង់រួមនៃស្ថានីយគុកម្រែង ឬ គុហ៍បារែង

## ១៩. វត្តឧទ្ទមព័រ

វត្តឧទ្ទមព័រ ស្ថិតក្នុងភូមិឧទ្ទមព័រ ឃុំស្រឡៅ។ នៅក្នុងបរិវេណវត្ត យើងប្រទះឃើញបំណែកថ្មភក់ពីរ ដុំដែលជាថ្មទម្រមួយបែកចេញពីគ្នាជាពីរដុំ។


បំណែកថ្មទម្របដិមាធ្វើពីថ្មភក់ក្នុងបរិវេណវត្ត


បំណែកថ្មទម្របដិមាធ្វើពីថ្មភក់ក្នុងបរិវេណវត្ត

## ២១. វត្តគុកព្រះធាតុ

ព្រះធាតុជាពាក្យសំដៅជាតុក្នុងព្រះពុទ្ធសាសនា។ ពោលយើងបានពិនិត្យឃើញសំណល់ព្រះពុទ្ធបដិមា សល់ភ្នែនក្នុងកាយវិការយកព្រះធរណីជាសាក្សី, ដងព្រះកាយនិងព្រះពុទ្ធប្រក់នាគក្នុងកាយវិការសមាធិ។

គុកព្រះធាតុ ស្ថិតនៅក្នុងឃុំស្រឡៅ។ នៅលើបរិវេណនៃសាឡាអំពីឈើ មានកំពែងថ្មបាយក្រៀម២ជាន់។ ស្លាកស្នាមកំពែងខាងក្រៅគឺសេសសល់ស្មើទៅនឹងផ្ទៃដី រីឯកំពែងខាងក្នុងយើងអាចមើលឃើញនៅជ្រុងខ្លះ។ តាមរយៈកំពែងទាំងពីរនេះ បញ្ជាក់ឱ្យដឹងថាទីតាំងតួប៉មរបស់គុកពីមុនគឺស្ថិតនៅចំសាឡាំឈើ តែយើងមិនអាចប៉ាន់ស្មានអំពីទំហំរបស់គុកនេះបានទេ គឺតម្រូវឱ្យមានការធ្វើកំណាយ។

ក្រៅពីនេះ ក៏ន)មានទម្របដិមាមេទ្វារចំនួន២ សន្ទឹកថ្មអឌ្ឍចន្ទ្រចំនួន២ ព្រះពុទ្ធបដិមាសម័យកណ្ដាល ព្រះពុទ្ធប្រក់នាគដែលមានតែភ្នែននិងដៃ។


ខឿនវិហារសង់ពីថ្មបាយក្រៀម



ខឿនខាងក្រៅនៅជាប់ផ្ទៃដី



ទម្របដិមា



ថ្មទ្រនាប់ជណ្ដើរនៅក្បែរសាឡុំ

## ២១. វត្តទួល

វត្តទួល ស្ថិតក្នុងឃុំឈូកខ្សាច់។ នៅក្នុងបរិវេណវត្ត ពុំមានស្លាកស្នាមបុរាណជាលក្ខណៈទួលគ្រឹះប្រាសាទបុរាណទេ។ ប៉ុន្តែនៅខាងមុខច្រកចូលមានទម្របដិមាមួយដុំសាងពីថ្មភក់ ស្ថិតនៅលើទួលមួយ ប៉ុន្តែទួលនេះត្រូវបានគេយកប្រើសម្រាប់ជាកន្លែងបញ្ចុះសព។



ទីទួលបញ្ចុះសពនៅខាងមុខវត្តទួល



ទម្របដិមាសាងពីថ្មភក់

# ឯកសារយោង

Aymonier, Etinne., Le Cambodge I Le Royume Actuel, Paris, 1900

Boisselier, Jean., Asie du Sud-Est : I. Le Cambodge, Paris, 1966, p. 151-152.

Lajonquière, E. Lunet., Invenaire Descriptif des Monuments du Cambodge, Tome I, 1902.

*មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ធំ, «តារាងស្ថិតិប្រាសាទ ទួល ស្រះ វត្តបុរាណ» ឆ្នាំ២០១៥។*